ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ០៣៦...ឧរថ.ធរ.អប

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

# អាជ្ញាប័ណ្ណស្វែងរុករក

(លើកទី២)

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់ភ្នំង៉ត ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន Gold Metal Group Co., Ltd ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករកលេខ ១២០៩ ឧរថ.ធរ.អប ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- លិខិតស្នើសុំពន្យារបន្តអាជ្ញាប័ណ្ណស្វែងរុករករ៉ែលោហៈ នៅតំបន់ភ្នំង៉ត ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន Gold Metal Group Co., Ltd លេខ:០៦២ ៨/០៨ GMG ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨ ។
- របាយការណ៍សុំកាត់បន្ថយផ្ទៃក្រឡាដីសម្បទានសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់ភ្នំង៉ត ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន Gold Metal Group Co., Ltd ចុះខែតុលា ឆ្នាំ២០០៨ ។

## សម្រេច

**ប្រការ១:** អនុញ្ញាតអោយក្រុមហ៊ុន Gold Metal Group Co., Ltd មានអាសយដ្ឋាននៅផ្ទះលេខ ៥៦ ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់ភ្នំង៉ត ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី លើផ្ទៃដីទំហំ១៣៤ (មួយរយសាមសិបបួន)គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A’ | 7 00 000 | 14 10 000 | F’ | 7 04 000 | 14 01 000 |
| B’ | 7 14 000 | 14 10 000 | G’ | 7 04 000 | 13 98 000 |
| C’ | 7 14 000 | 13 98 000 | H’ | 7 02 000 | 13 98 000 |
| D’ | 7 12 000 | 13 98 000 | I’ | 7 02 000 | 14 03 000 |
| E’ | 7 12 000 | 14 01 000 | J’ | 7 00 000 | 14 03 000 |

**ប្រការ២:** ក្រុមហ៊ុនត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែ លើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេស ក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

**ប្រការ៣:** អាជ្ញាប័ណ្ណនេះមានសុពលភាពរហូតដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០។ មុនផុតកំណត់ ៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំពន្យារបន្តអាជ្ញាប័ណ្ណស្វែងរុករករ៉ែបន្តជាថ្មី ។

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាជ្ញាប័ណ្ណនេះនឹងត្រូវព្យួរទុក ឬ ដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្ដីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តមណ្ឌលគិរី និងប្រធានក្រុមហ៊ុន Gold Metal Group Co., Ltd ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារៈកិច្ចរៀងៗខ្លួន ។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានសុពលភាពអនុវត្ត ចាប់ពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ តទៅ ។

**ចំលងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកពេជ្រាដា
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ